01043340

**Declassified to Public**
**09 June 2021**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

អង្គបុរេជំនុំជម្រះ
Pre-Trial Chamber
Chambre Préliminaire

ឯកសារលេខ៖ D117/1/1/2

*តាងនាមប្រជារាស្ត្រខ្មែរ និងតាងនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ*

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០៣/០៧-០៩-២០០៩-អវតក/កសចស (អបជ ១៣)

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គីមសាន ប្រធាន |
| | ចៅក្រម Rowan DOWNING |
| | ចៅក្រម ន៉ីយ ថុល |
| | ចៅក្រម Chang-Ho CHUNG |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 12 / 2014
ម៉ោង (Time/Heure): 14:15
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Sann Rada

# សម្ងាត់បំផុត

## សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់

<u>សហព្រះរាជអាជ្ញា៖</u>
ជា លាង
Nicholas KOUMJIAN

<u>សហមេធាវីការពារក្តីម្ចាស់បណ្តឹងឧទ្ធរណ៍៖</u>
អាង ឧត្តម
Michael G. CARNAVAS

<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី៖</u>
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Emmanuel JACOMY
Barnabe NEKUI
Lyma NGUYEN
Christine MARTINEAU
Beini YE

ទី ស្រ៊ុនណា

វ៉េន ពៅ

Annie DELAHAIE
Laure DESFORGES
Herve DIAKIESE
Ferdinand DIAMMEN-NZEPA

**អង្គបុរេជំនុំជម្រះ**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") បានទទួល "បណ្ដឹងឧទ្ធរណ៍មួយដែលបានដាក់នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤ ដោយសហមេធាវីរបស់ មាស មុត ("ម្ចាស់បណ្ដឹងឧទ្ធរណ៍") ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") លើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ("បណ្ដឹងឧទ្ធរណ៍")[1]។

## I. ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០១៤ សហមេធាវីបានបញ្ជូនលិខិតមួយទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ស្នើសុំព័ត៌មានអំពីលក្ខណៈនៃករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតជាតិ និងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះកាលបរិច្ឆេទថ្ងៃទី ០៧ និងថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ("ករណីខ្វែងយោបល់គ្នា") ដែលពួកគាត់ពុំអាចចូលទៅពិនិត្យមើលបានឡើយ[2]។ នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ ក.ស.ច.អ បានឆ្លើយតបដោយបញ្ជាក់ជូនដូចខាងក្រោមនេះ៖

> "២. ករណីខ្វែងយោបល់គ្នាទាំងអស់ គឺជាឯកសារសម្ងាត់បំផុត លើកលែងតែបញ្ហានានាដែលមានចែងនៅក្នុងវិធានផ្ទៃក្នុង ៧២(៤)(ខ)។ អាស្រ័យហេតុនេះ ស.ច.ស អន្តរជាតិ មិនស្ថិតនៅក្នុងតួនាទីមួយដែលត្រូវជូនដំណឹងលោកអំពីខ្លឹមសារ ឬលក្ខណៈទូទៅនៃករណីខ្វែងយោបល់គ្នាទាំងនោះទេ។ ការលើកយោងករណីខ្វែងយោបល់គ្នាបែបនោះនៅក្នុងសេចក្ដីសម្រេចនានារបស់ ក.ស.ច.ស គឺសុទ្ធតែជាការលើកយោងជាផ្លូវការដែលមានហត្ថលេខារបស់ចៅក្រមតែម្នាក់ប៉ុណ្ណោះ ហើយធ្វើឡើងក្នុងគោលបំណងដើម្បីបង្ហាញការគោរពតាមពេលវេលាពាក់ព័ន្ធ។
>
> ៣. ជាការជូនដំណឹងលោក *ករណីខ្វែងយោបល់គ្នាទាំងនោះ មិនទាន់បានដាក់ជូននៅ*

[1] បណ្ដឹងឧទ្ធរណ៍របស់ មាស មុត ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ D117/1/1/1។

[2] លិខិតពីសហចៅក្រមស៊ើបអង្កេត Harmon ផ្ញើជូនមេធាវីការពារក្ដី *សំណើសុំព័ត៌មាន ទាក់ទងនឹងកំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០១៣ និងថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣* ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៤ ឯកសារ D82/3/2 កថាខណ្ឌ ១។

*ចំពោះមុខអង្គបុរេជំនុំជម្រះទេ ហើយពេលវេលាសម្រាប់ការដាក់ជូននៅចំពោះមុខអង្គបុរេជំនុំជម្រះ តាមលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុង ៧២(២) មិនទាន់អស់សុពលភាពឡើយ*"[3]។

២. នៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ វិទ្យុសំឡេងសហរដ្ឋអាមេរិកបានចេញផ្សាយអត្ថបទមួយដែលបានបង្ហាញឲ្យដឹងថា អ៊ឹម ចែម ត្រូវបានកោះហៅឲ្យចូលបង្ហាញខ្លួននៅ អ.វ.ត.ក[4]។

៣. នៅថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤ ម្ចាស់បណ្ដឹងឧទ្ធរណ៍បានស្នើសុំឲ្យសហចៅក្រមស៊ើបអង្កេតផ្ដល់ការបំភ្លឺអំពីសុពលភាពនៃដីកាកោះ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ *ក្នុងគោលបំណងចោទប្រកាន់* ដោយអះអាង *ក្នុងចំណោមប្រការផ្សេងទៀត* ថា ច្បាប់មិនបានចែងច្បាស់លាស់ឡើយ ទាក់ទិននឹងសុពលភាពនៃដីកាកោះបែបនេះ("សំណើ")[5]។ សហមេធាវីបានលើកទឡ្ហីករណ៍នៅក្នុងសំណើថា ក្នុងករណីដែល "ស.ច.ស.អ" បានសម្រេចជា *ឯកតោភាគី* ក្នុងការកោះហៅ មាស មុត មេធាវីការពារក្ដីត្រូវការសំអាងហេតុផ្លូវច្បាប់ពីសហចៅក្រមស៊ើបអង្កេតទាំងពីររូប អំពីសុពលភាពនៃដីកាកោះបែបនេះ ដើម្បីអាចឲ្យមេធាវី "ផ្ដល់ប្រឹក្សាប្រកបដោយអត្ថន័យ" ជូនម្ចាស់បណ្ដឹងឧទ្ធរណ៍។ ជាចុងក្រោយ សហមេធាវីបានអះអាងថា ការកោះហៅជនសង្ស័យ មិនមែនជាកិច្ចស៊ើបអង្កេតទេ មិនដូចជាការកោះហៅសាក្សីឡើយ[6]។

៤. នៅថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ អង្គបុរេជំនុំជម្រះបានចេញសេចក្ដីសម្រេចមួយដោះស្រាយទៅលើសុពលភាពនៃដីកាកោះហៅជនសង្ស័យ ដែលបានចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ("សេចក្ដីសម្រេចរបស់ អ.ប.ជ លើសំណុំរឿង ០០៤")[7]។ នៅក្នុងករណីនោះ

---

[3] *ដូចយោងខាងលើ* កថាខណ្ឌ ២ និង ៣។

[4] សុខ ខេមរា ជនសង្ស័យខ្មែរក្រហមម្នាក់ទៀតនឹងចូលបង្ហាញខ្លួននៅសាលាក្ដីនៅថ្ងៃចន្ទ VOa Khmer ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៤ អាចរកមើលបាននៅលើគេហទំព័រ http://www.voacambodia.com/content/additional-khmer-rouge-suspect-to-appear-at-tribunal-monday/2409141.html

[5] សំណើសុំព័ត៌មាន ទាក់ទងនឹងសុពលភាពនៃដីកាកោះ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ឯកសារ D117 ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១៤។

[6] លិខិតពីសំណុំរឿង ០០៣ ផ្ញើជូន ក.ស.ច.ស *សំណើសុំព័ត៌មាន ទាក់ទងនឹងសុពលភាពនៃដីកាកោះ ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ D117។

[7] ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៩) សេចក្ដីសម្រេចលើសំណើបន្ទាន់របស់អ្នកស្រី អ៊ឹម ចែម សុំព្យួរការអនុវត្តដីកាកោះហៅអ្នកស្រីឲ្យមកបង្ហាញខ្លួនជាលើកដំបូង ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ A 122/6.1/3 កថាខណ្ឌ ១៤។

នៅពេលដែលសហចៅក្រមស៊ើបអង្កេតបានធ្វើកំណត់ហេតុករណីខ្វែងយោបល់គ្នា និងមិនបានយកករណីខ្វែងយោបល់គ្នានេះមកដាក់ចំពោះមុខអង្គបុរេជំនុំជម្រះក្នុងរយៈពេលកំណត់ ៣០ ថ្ងៃនោះ អង្គបុរេជំនុំជម្រះយល់ឃើញថា ដីកាកោះនោះមានសុពលភាព និងអនុលោមតាមកម្រងច្បាប់ អ.វ.ត.ក។

៥. នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤ ស.ច.ស.អ បានចេញសេចក្តីបំភ្លឺមួយ ឆ្លើយតបទៅនឹងសំណើមួយផ្សេងទៀត ស្រដៀងគ្នាទៅនឹងសំណើនោះដែរ ដែលបានដាក់ដោយជនសង្ស័យម្នាក់ទៀតនៅក្នុងសំណុំរឿង ០០៤ ("ការបំភ្លឺលើសំណុំរឿង ០០៤")[8]។

៦. បន្ទាប់មកទៀត នៅថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤ ស.ច.ស.អ បានចេញដីកាសម្រេចលើសំណើរបស់ជនសង្ស័យទាក់ទងនឹងដីកាកោះ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ("ដីកាសម្រេចដែលរងការជំទាស់")[9]។ ស.ច.ស.អ បានបំភ្លឺថា សុពលភាពនៃដីកាកោះហៅជនសង្ស័យណាម្នាក់ ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ មានចែងនៅក្នុងមាត្រា ៥ និង ៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធាន ៧២(៥) នៃវិធានផ្ទៃក្នុង[10]។ ស.ច.ស.អ បានបញ្ជាក់ជូនបន្ថែមទៀតដល់សហមេធាវី ពាក់ព័ន្ធនឹងទឡ្ហីករណ៍របស់ពួកគាត់ថា ការកោះហៅជនសង្ស័យណាម្នាក់ឱ្យមកបង្ហាញខ្លួនលើកដំបូង មិនមែនជាកិច្ចស៊ើបអង្កេតទេ ដែលស្ថិតនៅក្រោមក្របខណ្ឌនៃវិធាន ៧២ នៃវិធានផ្ទៃក្នុងទេ ហើយថា ស.ច.ស.អ បានដោះស្រាយបញ្ហានេះរួចហើយនៅក្នុងសំណុំរឿង ០០៤[11] និងបានបន្ថែមថា អង្គបុរេជំនុំជម្រះក៏បានបញ្ជាក់យ៉ាងច្បាស់ផងដែរអំពីអំណាចក្នុងការចេញដីកាកោះហៅជនសង្ស័យណាម្នាក់ ដែលមានសុពលភាព និងចេញតែម្នាក់ឯង នៅក្នុងកាលៈទេសៈបែបនេះ[12]។

---

[8] សំណុំរឿង ០០៤ ការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីសុពលភាពនៃដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ឯកសារ D117/1.1 ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១៤។

[9] ដីកាសម្រេចលើសំណើរបស់ជនសង្ស័យ ទាក់ទងនឹងដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ D117/1។

[10] *ដូចយោងខាងលើ* កថាខណ្ឌ ៣។

[11] *ដូចយោងខាងលើ* យោង ការបំភ្លឺ សំណុំរឿង ០០៤ កថាខណ្ឌ ១១:

[12] *ដូចយោងខាងលើ* កថាខណ្ឌ ៤ យោង សេចក្តីសម្រេចរបស់ អ.ប.ជ សំណុំរឿង ០០៤ ។



E.C.C.C. C.E.T.C. PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

៧. នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៤ ម្ចាស់បណ្តឹងឧទ្ធរណ៍បានដាក់បណ្តឹងឧទ្ធរណ៍។ ពុំមានការដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នៅក្នុងអំឡុងពេលវេលាកំណត់តាមច្បាប់ឡើយ។ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនបានស្នើសុំឱ្យមានសវនាការលើបណ្តឹងឧទ្ធរណ៍ឡើយ ទោះជាគាត់លើកទឡ្ហីករណ៍នៅក្នុងបណ្តឹងឧទ្ធរណ៍ថា "មេធាវីការពារក្តីត្រូវតែមានឱកាសឲ្យអង្គបុរេជំនុំជម្រះបានស្តាប់អំណះអំណាង នៅមុនពេលដែលសំអាងហេតុរបស់អង្គបុរេជំនុំជម្រះក្នុងរឿងក្តី ០០៤ មានអានុភាពជាយុត្តិសាស្ត្រនៅក្នុងរឿងក្តី ០០៣"[13]។ អង្គបុរេជំនុំជម្រះបានសម្រេចបន្តដំណើរការដោយផ្អែកលើសារណាជាលាយលក្ខណ៍អក្សរលើបណ្តឹងឧទ្ធរណ៍ ដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ឲ្យអង្គបុរេជំនុំជម្រះយល់ដឹងពេញលេញអំពីបញ្ហានានា ដែលម្ចាស់បណ្តឹងឧទ្ធរណ៍បានលើកឡើងនៅចំពោះមុខអង្គបុរេជំនុំជម្រះ។

## II. ឧឡឹករណ៍លើបណ្តឹងឧទ្ធរណ៍

៨. នៅក្នុងបណ្តឹងឧទ្ធរណ៍នេះ សហមេធាវីការពារក្តីបានស្នើសុំអង្គបុរេជំនុំជម្រះ៖ ១) ទទួលយកបណ្តឹងឧទ្ធរណ៍ និង ២) សម្រេចថា ដីកាកោះដែលចេញដោយសហចៅក្រមស៊ើបសង្កេតតែម្នាក់ឯង មិនមានសុពលភាពនោះទេ។

៩. សហមេធាវីការពារក្តីបានលើកឡើងថា បណ្តឹងឧទ្ធរណ៍អាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីការពារដល់*សិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់*។ ក្នុងគោលបំណងនេះ មេធាវីការពារក្តីបានយោងលើយុត្តិសាស្ត្រជាតិ[14] និងយុត្តិសាស្ត្រអន្តរជាតិ[15] ដើម្បីកំណត់អំពីលក្ខណវិនិច្ឆ័យដែលត្រូវយកច្បាប់មកអនុវត្ត ដើម្បីបញ្ជាក់ឲ្យច្បាស់តាមផ្លូវច្បាប់ដែលតម្រូវថា ច្បាប់ "ត្រូវតែច្បាស់លាស់ និងជាក់លាក់ត្រឹមត្រូវ ព្រមទាំងងាយស្រួលរក និងអាចយល់បាន"[16]។ សហមេធាវីការពារក្តីបានលើកឡើងបន្ថែមថា ទោះបីគោលការណ៍សច្ចភាពផ្លូវច្បាប់មិនមានចែងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ក៏គោលការណ៍នេះគឺជាគោលការណ៍ច្បាប់ដែលទទួលស្គាល់នៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានការពារតាមរយៈសិទ្ធិ

[13] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៧។

[14] បណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១១។

[15] ដូចខាងលើដែរ កថាខណ្ឌ ១២។

[16] *ដូចខាងលើដែរ* កថាខណ្ឌ ១១។

ប្រជាពលរដ្ឋក្នុងការប្ដឹងឧទ្ធរណ៍ទៅលើធម្មនុញ្ញភាពនៃច្បាប់[17] តាមរយៈសិទ្ធិនៃការការពារខ្លួន ដែលត្រូវបានធានាដោយដំណោះស្រាយតាមផ្លូវតុលាការ និងដោយការគោរពចំពោះសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌[18]។ មេធាវីការពារក្ដីលើកឡើងថា ដំណោះស្រាយតុលាការ មិនអាចគ្រប់គ្រាន់ ហើយសិទ្ធិក្នុងការទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ មិនអាចត្រូវបានគេគោរពទេ នៅពេលដែលវិធាននីតិវិធី មិនច្បាស់លាស់ និងមិនប្រាកដប្រជា។ នៅក្នុងចំណុចនេះ តាមតែមេធាវីការពារក្ដីដឹង ច្បាប់ទាក់ទិននឹងដីកាកោះនៅ អ.វ.ត.ក មិនច្បាស់លាស់ត្រង់ចំណុច ថាតើសហចៅក្រមស៊ើបអង្កេតអាចបំពេញកិច្ចតែម្នាក់ឯងដែរឬទេ។ បន្ថែមពីលើនេះទៀត សហមេធាវីការពារក្ដីលើកឡើងថា នៅក្នុងសំណុំរឿង ០០៣ បញ្ហានេះមិនទាន់ត្រូវបានដោះស្រាយទេ ហេតុដូច្នេះ សេចក្ដីសម្រេចដែលចេញនៅក្នុងសំណុំរឿង ០០៤ មិនអាចបំពេញតួនាទីជាយុត្តិសាស្ត្រនោះទេ ពីព្រោះម្ចាស់បណ្ដឹងឧទ្ធរណ៍មិនមែនជាភាគីមួយនៃសំណុំរឿង ០០៤ នោះទេ[19]។ នៅក្នុងករណីណាក៏ដោយ មេធាវីការពារក្ដីតវ៉ាថា "សំអាងហេតុនៅក្នុងសេចក្ដីសម្រេច អ.ប.ជ ក្នុងរឿងក្ដី ០០៤ហាក់បីដូចជាមិនត្រឹមត្រូវ"[20]។ ជាចុងក្រោយ សហមេធាវីការពារក្ដីលើកទឡ្ហីករណ៍ថា បណ្ដឹងឧទ្ធរណ៍គួរតែទទួលយក តាមរយៈការបកស្រាយទូលាយលើសិទ្ធិក្នុងការប្ដឹងឧទ្ធរណ៍ អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[21]។

១០. ទឡ្ហីករណ៍ទីមួយ សហមេធាវីការពារក្ដីលើកទឡ្ហីករណ៍ថា មាត្រា ៥(៤) នៃកិច្ចព្រមព្រៀង និងមាត្រា ២៣ ថ្មី នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ព្រមទាំងវិធាន ១(២) នៃវិធានផ្ទៃក្នុង ត្រូវតែ

[17] *ដូចខាងលើដែរ* កថាខណ្ឌ ១២ ដែលយោងទៅលើមាត្រា ១៤១ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ១៩៩៤ ដែលវិសោធនកម្មដោយព្រះរាជក្រមចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសវិសោធនកម្មលើមាត្រា១១, ១២, ១៣, ១៨, ២២, ២៤, ២៦, ២៨, ៣០, ៣៤, ៥១, ៩០, ៩១, ៩៣ និងមាត្រាផ្សេងទៀត ចាប់ពីជំពូក៨ ដល់ជំពូក១៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលអនុម័តដោយរដ្ឋសភាជាតិកាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ១៩៩៩។

[18] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១២។

[19] *ដូចខាងលើដែរ* កថាខណ្ឌ ១៤។

[20] *ដូចខាងលើដែរ* កថាខណ្ឌ ១៤។

[21] *ដូចខាងលើដែរ* កថាខណ្ឌ ១៤។ យោងលើ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៦៦ និងសេចក្ដីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4។

បកស្រាយក្នុងន័យតម្រូវឱ្យសហចៅក្រមស៊ើបបំពេញកិច្ចរួមគ្នា[22]។ នៅក្នុងចំណុចនេះ សហមេធាវីការពារក្ដីបន្ថែមថា ករណីលើកលែងចំពោះការបកស្រាយនេះ មាននៅក្នុង*ការផ្ទេរសិទ្ធិអំណាច* របស់សហចៅក្រមស៊ើបអង្កេតមួយរូប ទៅសហចៅក្រមស៊ើបអង្កេតមួយរូបផ្សេងទៀត ដោយបានរម្លឹកថា មិនមានការចង្អុលបង្ហាញណាមួយដែលថា សហចៅក្រមស៊ើបអង្កេតជាតិ បានផ្ទេរសិទ្ធិអំណាចរបស់គាត់ក្នុងការចុះហត្ថលេខាលើដីកាកោះរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ[23]។ បន្ថែមពីលើនេះ *ដោយសន្មត* ថា ដីកាកោះឱ្យ*បង្ហាញខ្លួនជាលើកដំបូង* គឺជា "ដីកាកោះ *ក្នុងគោលបំណងធ្វើការចោទប្រកាន់*" សហមេធាវីការពារក្ដីលើកទឡ្ហីករណ៍ថា ដើម្បីចោទប្រកាន់ជនសង្ស័យ វិធានផ្ទៃក្នុងតម្រូវឱ្យមានអត្ថិភាពនៃ "ភស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នា"[24] ហេតុដូច្នេះ ប្រសិនបើសហចៅក្រមស៊ើបអង្កេតខ្វែងយោបល់គ្នាលើចំណុចនេះ ភស្តុតាងមិនអាចចាត់ទុកថាច្បាស់ និងស៊ីសង្វាក់គ្នានោះទេ ដោយករណីនេះធ្វើឱ្យ "មិនត្រឹមត្រូវ ដែលសហចៅក្រមស៊ើបអង្កេតមួយរូប ចេញដីកាកោះ និងធ្វើការចោទប្រកាន់ទៅលើជនសង្ស័យដោយរូបគាត់តែម្នាក់ឯងនោះ"[25]។ សហមេធាវីបានលើកឡើងថា នៅពេលដែលមាន *មន្ទិលសង្ស័យ* ថាមានបញ្ហាបែបនេះកើតមាន រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងអំពីដំណោះស្រាយដោយឱ្យជាប្រយោជន៍ដល់ខាងមេធាវីការពារក្ដី[26]។

១១. ទឡ្ហីករណ៍ទីពីរ សហមេធាវីការពារក្ដីលើកឡើងថា កិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មិនបានចែងឱ្យសហចៅក្រមស៊ើបអង្កេតមួយរូបចេញដីកាកោះតែម្នាក់ឯងនៅក្នុងករណីមានការខ្វែងយោបល់គ្នានោះទេ[27]។ ដោយសារតែ មាស មុត បានជូនដំណឹងម្ដងហើយម្ដងទៀតដល់សហចៅក្រមស៊ើបអង្កេតថា គាត់មិនមានបំណងឆ្លើយទៅនឹងសំណួរណាមួយនោះទេ ហើយគាត់នឹង*ប្រើប្រាស់សិទ្ធិនៅស្ងៀមមិនឆ្លើយតប* ដូច្នេះសហមេធាវីការពារក្ដី សន្មតថា "ការកោះហៅលោក មាស មុត *អាចធ្វើឡើងតែក្នុងគោលបំណងចោទប្រកាន់គាត់ប៉ុណ្ណោះ*"[28]។ មេធាវីការពារក្ដី

---

[22] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ២៣ និង២៤។

[23] *ដូចខាងលើដែរ* កថាខណ្ឌ ២៥។

[24] *ដូចខាងលើដែរ* កថាខណ្ឌ ២៦ *យោងលើ*វិធាន៥(៤)នៃវិធានផ្ទៃក្នុង។

[25] *ដូចខាងលើដែរ* កថាខណ្ឌ ២៦។

[26] *ដូចខាងលើដែរ*។

[27] *ដូចខាងលើដែរ* កថាខណ្ឌ ២៧-៣០។

[28] *ដូចខាងលើដែរ* កថាខណ្ឌ ២៩។



ECCC C.E.T.C PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE

លើកទឡ្ហីករណ៍ថា ដីកាកោះប្រភេទនេះ មិនទាក់ទងទៅនឹងថាតើការស៊ើបអង្កេតអាចបន្ត ឬមិនបន្តនោះទេ ប៉ុន្តែ*ទាក់ទងថាតើជាចុងក្រោយការជំនុំជម្រះអាចដំណើរការ ឬមិនដំណើរការ*។ មេធាវីការពារក្ដីក៏លើកឡើងបន្តទៀតថា កិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មិនបានលើកឡើងអំពីស្ថានភាពបែបនេះទេ ហើយយុត្តិសាស្ត្រពីមុនរបស់ អ.ប.ជ ដែលអង្គបុរេជំនុំជម្រះបានបដិសេធទឡ្ហីករណ៍ដែលថា កិច្ចដែលបំពេញដោយចៅក្រមស៊ើបអង្កេត Lemonde តែម្នាក់ឯងក្នុងការកោះហៅ*សាក្សី* មិនមានសុពលភាពនោះ យុត្តិសាស្ត្រនេះមិនពាក់ព័ន្ធនៅក្នុងរឿងក្ដីបច្ចុប្បន្ននេះទេ ដោយសារតែកិច្ចបែបនេះទាក់ទងតែចំណុចថាតើ *ការស៊ើបអង្កេត* អាចបន្ត ឬមិនបន្ត នេះបើតាមមេធាវីការពារក្ដី[29]។

១២. ទឡ្ហីករណ៍ទីបី សហមេធាវីការពារក្ដីបានលើកឡើងថា វិធាន៧២(៣)នៃវិធានផ្ទៃក្នុង មិនអាចយកមកធ្វើជាមូលដ្ឋានសម្រាប់ឱ្យសហចៅក្រមស៊ើបអង្កេតតែមួយរូបចេញដីកាកោះឡើយ ដោយសារតែនៅពេលចែងថា "សកម្មភាព ឬសេចក្ដីសម្រេចទាំងអស់ដែលជាកម្មវត្ថុនៃការខ្វែងយោបល់គ្នានឹងត្រូវបានអនុវត្ត" វិធាននេះចែងហួសពីអ្វីដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ដែលតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការងាររួមគ្នា[30]។

១៣. ទឡ្ហីករណ៍ចុងក្រោយ សហមេធាវីការពារក្ដីលើកឡើងថា ទោះបីជាច្បាប់ជាធរមានអាចត្រូវបានបកស្រាយថាអនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតបំពេញកិច្ចតែឯង ក្នុងការកោះហៅជនសង្ស័យ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គង ដោយមិនបានដាក់កម្រិតកំណត់ទៅលើ *ពេលដែល* សហចៅក្រមស៊ើបអង្កេតអាចចេញដីកាកោះតែម្នាក់ឯងបាន[31]។ មេធាវីការពារក្ដីជំទាស់ថា ពាក្យពេចន៍ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានប្រើ នៅក្នុងដីកាសម្រេចដែលរងការជំទាស់ថា "ដីកាកោះជនសង្ស័យណាម្នាក់ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់គឺមានសុពលភាព និងជាប់កាតព្វកិច្ច"[32] *បានពង្រីកការអនុវត្ត* មូលដ្ឋាននេះ ឱ្យមានន័យថា ការធ្វើបែបនេះ *តែងតែ* ត្រូវបានអនុញ្ញាត។ ដោយអះអាងថា ខ្លួនមិនបានដឹង "ថាតើសហចៅក្រមស៊ើបអង្កេតខ្វែងយោបល់គ្នាអំពីបញ្ហាថាតើត្រូវកោះហៅលោក មាស មុត ឬយ៉ាងណានោះ"

---

[29] *ដូចខាងលើដែរ* កថាខណ្ឌ ២៨ និង៣០។

[30] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣១ និង៣៣។

[31] បណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ៣៤ និង៣៥។

[32] *ដូចខាងលើដែរ* កថាខណ្ឌ ៣៤ *ដែលដកស្រង់* ដីកាសម្រេចដែលរងការជំទាស់ កថាខណ្ឌ៥។

និងយោងទៅលើសំអាងហេតុរបស់សេចក្ដីសម្រេច អ.ប.ជ ក្នុងរឿងក្ដី ០០៤ មេធាវីការពារក្ដី ស្នើសុំឲ្យអង្គបុរេជំនុំជម្រះបង្គាប់ដល់ ស.ច.ស.អ ថា មុនពេលកោះហៅជនសង្ស័យ *ក្នុងគោលបំណងចោទប្រកាន់* ស.ច.ស.អ "ដំបូងត្រូវធ្វើកំណត់ហេតុអំពីការខ្វែងយោបល់គ្នាជាមួយសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង និងរង់ចាំរហូតដល់៣០ថ្ងៃនៃរយៈពេលដោះស្រាយការខ្វែងយោបល់គ្នាបានកន្លងផុត ឬក៏រហូតដល់ពេលដែលសហចៅក្រមស៊ើបអង្កេត យូ ប៊ុនឡេង បញ្ជូនការខ្វែងយោបល់គ្នាទៅអង្គបុរេជំនុំជម្រះ"[33]។

## III. ភាពទទួលយកបាន

១៤. ម្ចាស់បណ្ដឹងឧទ្ធរណ៍មិនបានអះអាងថា បណ្ដឹងឧទ្ធរណ៍អាចទទួលយកបានអនុលោមតាមវិធាន ៧៣ ឬ វិធាន ៧៤ នៃវិធានផ្ទៃក្នុង ដែលចែងច្បាស់ពីយុត្តាធិការរបស់អង្គបុរេជំនុំជម្រះទេ តែលើកទឡ្ហីករណ៍ថា អង្គបុរេជំនុំជម្រះគួរប្រកាសថា បណ្ដឹងឧទ្ធរណ៍នេះអាចទទួលយកបាន អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង ដើម្បីការពារសិទ្ធិរបស់ជនសង្ស័យ ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់។ វិធាននេះចែងក្នុងផ្នែកដែលពាក់ព័ន្ធថា៖

**<u>វិធាន ២១. គោលការណ៍ជាសារវ័ន្ត</u>**

> ១. ច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្ដីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងកិច្ចព្រមព្រៀង។

១៥. អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា គោលកាណ៍ជាសារវ័ន្តដែលបានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលឆ្លុះបញ្ចាំងអំពីលក្ខខណ្ឌតម្រូវឲ្យមានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ដែល អ.វ.ត.ក ជាប់កាតព្វកិច្ចត្រូវអនុវត្តតាមមាត្រា ១៣(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហ

[33] *ដូចខាងលើដែរ* កថាខណ្ឌ ៣៤ និង៣៦។

ប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា[34] មាត្រា ៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[35] និង មាត្រា ១៤(៣) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[36] អាចតម្រូវថា សាលាក្តីនេះត្រូវប្រើប្រាស់ការបកស្រាយបែបបើកទូលាយចំពោះសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ដើម្បី ធានាថា កិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅដោយត្រឹមត្រូវយុត្តិធម៌ និងចំពោះមុខ ហើយត្រូវរក្សាឱ្យ បាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគី[37]។ នៅពេលដែលអង្គហេតុ និងកាលៈទេសៈពិសេសតម្រូវ អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍នានាដែលលើកឡើងពីសិទ្ធិជាសារវ័ន្ត ឬ "បញ្ហាធ្ងន់ ធ្ងរនៃភាពត្រឹមត្រូវយុត្តិធម៌" អនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[38]។ ទាក់ទងនឹងបញ្ហានេះ

---

[34] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវ ឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣។

[35] ច្បាប់ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈ កាលនៃកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងវិសោធនកម្មដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ ស្តីពីការបង្កើត អ.វ.ត.ក")។

[36] *សូមមើល ឧទាហរណ៍* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ("សំណុំរឿង ០០២") (អបជ ៦៤) សាល ដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត សម្រេចបដិសេធសំណើសុំ អនុញ្ញាតថតសំឡេង/រូបភាពវីដេអូ នៃការជួបជាមួយលោក អៀង សារី នៅក្នុងមន្ទីរឃុំឃាំង ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១០ ឯកសារ A371/2/12 កថាខណ្ឌ ១៣ ដល់ ១៨, ២៧។

[37] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ ១១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកា សម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ឯកសារ A190/I/20 កថាខណ្ឌ ៣៦។ សំណុំរឿង ០០២ (អបជ ៧១) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្តី សម្រេចរបស់ ក.ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋាន ស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្តីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១០ ឯកសារ D390/1/2/4 ("សាលដីកាលើចម្លើយតបរបស់ អៀង សារី") កថាខណ្ឌ ១៣។ សំណុំរឿង ០០២ (អបជ ១៤) សេចក្តីសម្រេចលើការជូនដំណឹងរបស់មេធាវីការពារក្តីស្តីពីកំហុសក្នុងការបកប្រែ ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១០ ឯកសារលេខ ២ ("សេចក្តីសម្រេចស្តីពីកំហុសក្នុងការបកប្រែ") កថាខណ្ឌ ៣។ សំណុំរឿង ០០២ (អបជ ៧៥) សាល ដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៩។

[38] *សូមមើល ឧទាហរណ៍* សំណុំរឿង ០០២ (អបជ ៤២) សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អ្នកស្រី អៀង ធីរិទ្ធ ប្រឆាំងនឹង ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត បដិសេធលើសំណើសុំព្យួរកិច្ចស៊ើបសួរ ដោយមូលហេតុរំលោភនីតិវិធី (D264/1) ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១០ ឯកសារ D264/2/6 កថាខណ្ឌ ១៣ ដល់ ១៤។ សាលដីកាលើចម្លើយតបរបស់ អៀង សារី កថាខណ្ឌ ១៣ *និង* សេចក្តីសម្រេចស្តីពីកំហុសក្នុងការបកប្រែ កថាខណ្ឌ ២ ដល់ ៦។

វិធាន ២១ នៃវិធានផ្ទៃក្នុងមិនបានផ្តល់សិទ្ធិដោយស្វ័យប្រវត្តិសម្រាប់បណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីទឡ្ហីករណ៍នានាដោយផ្អែកលើសិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌ទេ។ ដើម្បីឱ្យអង្គបុរេជំនុំជម្រះអាចអនុវត្តយុត្តាធិការលើបណ្តឹងឧទ្ធរណ៍ តាមវិធានដែលបានលើកឡើងបាន ម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបង្ហាញថា នៅក្នុងកាលៈទេសៈពិសេសៗនៃរឿងក្តី ការអន្តរាគមន៍របស់អង្គបុរេជំនុំជម្រះគឺជាការចាំបាច់ក្នុងការទប់ស្កាត់មិនឱ្យមានព្យសនកម្ម ដែលមិនអាចជួសជុលបានដល់ភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធី ឬសិទ្ធិរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌។ នាពេលថ្មីៗនេះ អង្គបុរេជំនុំជម្រះសម្រេចមិនទទួលយកបណ្តឹងឧទ្ធរណ៍មួយទៀតរបស់ម្ចាស់បណ្តឹងឧទ្ធរណ៍ ស្នើសុំការបំភ្លឺទៅលើច្បាប់ពាក់ព័ន្ធនឹងសេណារីយ៉ូបែបសម្មតិកម្ម ដោយអនុលោមតាមវិធាន ២១ នៃវិធានផ្ទៃក្នុង[39]។ អង្គបុរេជំនុំជម្រះបានសម្រេចថា "សិទ្ធិក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់ និងតម្លាភាពនៃកិច្ចដំណើរការនីតិវិធី ពុំតម្រូវថា ស្ថាប័នតុលាការត្រូវដោះស្រាយបញ្ហាផ្នែកអង្គច្បាប់ មុនពេលបញ្ហាទាំងនោះកើតឡើងពិតប្រាកដចេញពីសាវតារបរិបទ និងអង្គហេតុនៃបញ្ហាទាំងនោះឡើយ" និងបានសន្និដ្ឋានថា អង្គបុរេជំនុំជម្រះ "ពុំមានយុត្តាធិការដើម្បីដោះស្រាយបញ្ហាជាសម្មតិកម្ម ឬផ្តល់នូវមតិយោបល់ណែនាំនោះទេ"[40]។

១៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា ទោះបីសំណើសុំការបំភ្លឺស្នើសុំមតិយោបល់ណែនាំទៅលើបញ្ហាជាសម្មតិកម្មក៏ដោយ ក៏ ស.ច.ស.អ បានជ្រើសរើសយកឆ្លើយតបចំពោះសំណើ តាមរយៈសេចក្តីសម្រេចដែលរងការជំទាស់។ នាពេលនេះ ម្ចាស់បណ្តឹងឧទ្ធរណ៍ស្នើសុំជំទាស់ទៅនឹងខ្លឹមសារនៃការបំភ្លឺរបស់ ស.ច.ស.អ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និងស្នើឱ្យអង្គបុរេជំនុំជម្រះបង្ហាញការយល់ឃើញរបស់ខ្លួនចំពោះអង្គច្បាប់ ដោយលើកជាទឡ្ហីករណ៍ថា នេះជាផ្នែកមួយនៃសិទ្ធិរបស់គាត់ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់។ ដូចដែល ស.ច.ស.អ បានរម្លឹកនៅក្នុងសេចក្តីសម្រេចដែលរងការជំទាស់រួចមកហើយ អង្គបុរេជំនុំជម្រះធ្លាប់បានសម្រេចថា ដីកាកោះហៅជនសង្ស័យដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ក្នុងគោលបំណងចោទប្រកាន់ជនសង្ស័យ មានសុពលភាព ប្រសិនបើនីតិវិធីនៃការខ្វែងយោបល់គ្នាដែលមានចែងក្នុងវិធាន ៥៧ នៃវិធានផ្ទៃក្នុង

[39] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ D205/1/1/2។

[40] *ដូចយោងខាងលើ* កថាខណ្ឌ ៩។

ត្រូវបានអនុវត្តរួច ហើយរយៈពេល ៣០ ថ្ងៃសម្រាប់ការដាក់សំណើនៅចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុតហើយ[41]។ ចំពោះបទដ្ឋានសម្រាប់ការចោទប្រកាន់ជនសង្ស័យវិញ បទដ្ឋាននេះត្រូវបានចែងច្បាស់ក្នុងវិធាន ៥៥(៤) នៃវិធានផ្ទៃក្នុង។ ចំពោះករណីថាតើ ក្នុងករណីពិសេសនេះថាតើបទដ្ឋាននេះត្រូវបានបំពេញ ឬក៏អត់នោះ គឺជាបញ្ហាដែលមិនអាចយកមកពិនិត្យតាមបែបអរូបីបានទេ។ នៅក្នុងកាលៈទេសៈទាំងនេះ អង្គបុរេជំនុំជម្រះសន្និដ្ឋានថា ទឡ្ហីករណ៍របស់ម្ចាស់បណ្តឹងឧទ្ធរណ៍ដែលថា ការបកស្រាយច្បាប់របស់ ស.ច.ស.អ ដែលមានរៀបរាប់ក្នុងសេចក្តីសម្រេចដែលរងការជំទាស់ បានធ្វើឱ្យប៉ះពាល់សិទ្ធិរបស់គាត់ ក្នុងការទទួលបានសច្ចភាពផ្លូវច្បាប់នោះ មិនមានមូលដ្ឋានទេ។

១៧. ហេតុនេះ អង្គបុរេជំនុំជម្រះយល់ថា បណ្តឹងឧទ្ធរណ៍នេះមិនអាចទទួលយកបានទេ។

## IV. សេចក្តីសម្រេច

**អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆ័ន្ទថា៖**

**មិនទទួល** យកបណ្តឹងឧទ្ធរណ៍នេះ។

អនុលោមតាមវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង សេចក្តីសម្រេចនេះបិទផ្លូវតវ៉ា។

ភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១៤

**ប្រធាន** **អង្គបុរេជំនុំជម្រះ**

**ប្រាក់ គឹមសាន** **Rowan DOWNING** **ន័យ ថុល** **Chang-Ho CHUNG** **ហួត វុទ្ធី**

[41] សេចក្តីសម្រេចដែលរងការជំទាស់ កថាខណ្ឌ ៤ លើកយោងទៅសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើសំណុំរឿង ០០៤ កថាខណ្ឌ ១៤ ដែលម្ចាស់បណ្តឹងឧទ្ធរណ៍ត្រូវបានអនុញ្ញាតឱ្យមើលបាន។